**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៤១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### ស ម្រេ ច

**មាត្រា ១.-**

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន ៦០០ រៀល ទៅ ៧២០ រៀល ក្នុងមួយសន្ទស្សន៍ ។

**មាត្រា ២.-**

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា ១ ខាងលើ ត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្តផងដែរចំពោះកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងនិវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

www.pheakdeylaw.com

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០១ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com